# ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# MINISTRY OF LABOUR AND VOCATIONAL TRAINNING

## បទបង្ហាញ
## ស្តីពី
## ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
## សម្រាប់មន្ត្រីសាធារណៈនិងអ្នកក្នុងបន្ទុក និងផ្នែកហានិភ័យការងារ

រៀបចំដោយ បេឡាជាតិសន្តិសុខសង្គម

# មាតិកា

I.របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

II.របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

III.កម្មវិធីផ្តល់សាច់ប្រាក់ឧបត្ថម្ភជូនស្ត្រីជាមន្ត្រីសាធារណៈ

# I.របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

១.វិសាលភាព
២.លក្ខខណ្ឌនៃការចុះបញ្ជី
៣.ការបង់ភាគទាន
៤.លក្ខខណ្ឌប្រើសេវា
៥.អត្ថប្រយោជន៍(តាវកាលិក)
៦.លក្ខខណ្ឌទទួលបានប្រាក់បំណាច់និងវិភាជន៍បូជាសព
៧.សេវាបង្ការ
៨.សេវាមិនរាប់បញ្ចូល
៩.ជំងឺរ៉ាំរ៉ៃ
១០.ការទាមទារអត្ថប្រយោជន៍ជាសាច់ប្រាក់

# ១.វិសាលភាព

| មន្ត្រីសាធារណៈ | សហព័ទ្ធនិងកូនក្នុងបន្ទុក |
|---|---|
| ក.មន្ត្រីរាជការក្នុងក្របខណ្ឌមុខងារសាធារណៈនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនិងស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា<br>ខ.មន្ត្រីរាជការក្នុងស្ថាប័ននីតិប្បញ្ញត្តិលើកលែងផ្នែកសោធន<br>គ.មន្ត្រីរាជការក្នុងស្ថាប័នតុលាការ<br>ឃ.មន្ត្រីនគរបាលជាតិនិងមន្ត្រីពន្ធនាគារ ចំពោះតាវកាលិក ព្យាបាលនិងថែទាំវេជ្ជសាស្ត្រក្នុងផ្នែកថែទាំវេជ្ជសាស្ត្រ ក្នុងផ្នែកថែទាំសុខភាព<br>ង.មន្ត្រីបម្រើការងារនៅគ.ជ.ប<br>**ច**.អាជ្ញាធរសវនកម្មជាតិ<br>**ឆ**.អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន<br>ញ.មន្ត្រីជាប់កិច្ចសន្យាដែលទទួលស្គាល់ដោយក្រសួងមុខងារសារធារណៈ។ | សហព័ទ្ធនិងកូនរបស់មន្ត្រីសាធារណៈដែលកំពុងបម្រើការងារ។<br>➢ **សហព័ទ្ធ**មានន័យថា សំដៅដល់ប្តីឬប្រពន្ធឬទាំងប្តីប្រពន្ធដែលទទួលបានឋានៈជាសហព័ទ្ធនេះក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។<br>➢ **កូនក្នុងបន្ទុក**មានន័យថា សំដៅដល់កូនបង្កើតដែលមានសំបុត្របញ្ជាក់កំណើតឬកូនសុំដែលបានសុំស្របតាមបទប្បញ្ញត្តិជាធរមានឬក្មេងកំព្រារស់នៅក្នុងបន្ទុកផ្ទាល់របស់សមាជិកប.ស.ស.និងមានអាយុក្រោម១៨ឆ្នាំព្រមទាំងពុំមានប្រកបមុខរបរឬការងារដែលមានប្រាក់ចំណូលវៀរលែងតែកូនមានពិការភាពឬមានជំងឺរ៉ាំរ៉ៃដែលនៅក្នុងបន្ទុកផ្ទាល់។ |

# ២.លក្ខខណ្ឌនៃការចុះបញ្ជី

| មន្ត្រីសាធារណៈ | ប្ដីឬប្រពន្ធនិងកូនក្នុងបន្ទុក |
|---|---|
| ការចុះបញ្ជីឲ្យមន្ត្រីសាធារណៈតាមរយៈ<br>➢ ក្រសួងមុខងារសាធារណៈ<br>➢ អគ្គលេខាធិការដ្ឋានរដ្ឋសភា ព្រឹទ្ធសភា និង ក្រុមប្រឹក្សាធម្មនុញ្ញ | ប្ដីឬប្រពន្ធត្រូវមាន៖<br>❖ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ<br>❖ សៀវភៅស្នាក់នៅឬសៀវភៅគ្រួសារ<br>❖ សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍<br>❖ **សាមីខ្លួនត្រូវមកទីស្នាក់ការប.ស.ស.ដោយផ្ទាល់។**<br>កូនក្នុងបន្ទុកត្រូវមាន៖<br>❖ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬ<br>❖ សៀវភៅស្នាក់នៅឬសៀវភៅគ្រួសារ<br>❖ សេចក្ដីចម្លងសំបុត្រកំណើត<br>❖ ឪពុកឬម្ដាយត្រូវនាំកូនមកដោយផ្ទាល់នៅទីស្នាក់ការប.ស.ស.។ |

# ៣.ការបង់ភាគទាន

| មន្ត្រីសាធារណៈ | ប្តីឬប្រពន្ធនិងកូនក្នុងបន្ទុក |
|---|---|
| បន្ទុករបស់រដ្ឋាភិបាល | បន្ទុករបស់រាជរដ្ឋាភិបាល |
| អត្រាភាគទាននៃ១,៩%នៃប្រាក់បៀវត្សមូលដ្ឋានឬប្រាក់កម្រៃប្រចាំខែ | បង់ក្នុង១ខែ១,៩%x៨៧០,០០០រៀល |

# ៤.លក្ខខណ្ឌប្រើសេវា

| មន្ត្រីសាធារណៈ | ប្តីឬប្រពន្ធនិងកូនក្នុងបន្ទុក |
|---|---|
| ចូលបម្រើការងារមានសិទ្ធិប្រើតែម្តង។<br><br>**សម្គាល់**<br>ពេលចូលប្រើសេវានៅមន្ទីរពេទ្យដៃគូរ**ប.ស.ស**. ត្រូវភ្ជាប់មកជាមួយបណ្ណសមាជិក**ប.ស.ស**.និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ | ពេលចុះបញ្ជីរួចមានសិទ្ធប្រើប្រាស់តែម្តង។<br><br>**សម្គាល់**<br>ពេលចូលប្រើសេវានៅមន្ទីរពេទ្យដៃគូរ **ប.ស.ស**. ត្រូវភ្ជាប់មកជាមួយបណ្ណសមាជិក**ប.ស.ស**.។ |

# ៥.អត្ថប្រយោជន៍(តាមការលិកផ្នែកថែទាំសុខភាព)

| មន្ត្រីសាធារណ: | ប្តីឬប្រពន្ធនិងកូនក្នុងបន្ទុក |
|---|---|
| ១.ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ<br>ក.ការផ្តល់សេវាព្យាលបាលក្នុងមន្ទីរពេទ្យ<br>ខ.ការផ្តល់សេវាពិគ្រោះជំងឺក្រៅ<br>គ.សេវាសម្រាលកូន ថែទាំព្យាបាលមុននិងក្រោយសម្រាល<br>ឃ.សេវាព្យាបាលដោយស្តុំ ដោយចលនា ឬសេវាស្តានីតិសម្បទា ផ្នែកវេជ្ជសាស្ត្រ<br>ង.សេវាសង្គ្រោះបន្ទាន់<br>ច.សេវាបង្ការសុខភាព<br>ឆ.សេវាបញ្ជូនអ្នកជំងឺ ឬដឹកសព<br>២.ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ(រក្សាប្រាក់បៀវត្សនៅដដែល)<br>៣.ប្រាក់បំណាច់មាតុភាព(រក្សាប្រាក់បៀវត្សនៅដដែល)<br>៤.វិភាជន៍បូជាសព ២លាន ពីស្ថាប័នសាមី។ | ១.ដូចគ្នានឹងចំណុចលេខ១នៃថែទាំសុខភាពបុគ្គលសាធារណ:<br>២.ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ (រងចាំលិខិតបទដ្ឋានបន្ថែម)<br>៣.ប្រាក់បំណាច់មាតុភាពទទួលបាន៧០%នៃប្រាក់ចំណូល៨៧០,០០០រៀលស្មើ១,៨២៧,០០០រៀល<br>៤.វិភាជន៍បូជាសព កំណត់ដោយប្រកាសរបស់ក្រសួង (ទទួលពីប.ស.ស.)។ |

# ៦.លក្ខខណ្ឌដើម្បីទទួលបានប្រាក់បំណាច់ និងវិភាជន៍បូជាសព

| ប្រភេទ | ថៃទាំសុខភាពវិស័យសាធារណ: | ប្តីឬប្រពន្ធនិងកូនក្នុងបន្ទុក |
|---|---|---|
| ប្រាក់បំណាច់ឈប់សម្រាកពេលឈឺឬគ្រោះថ្នាក់ | • ត្រូវសុំច្បាប់និងមានលិខិតរបស់មូលដ្ឋានសុខាភិបាល<br>• រក្សាបៀវត្សនៅដដែល | រង់ចាំប្រកាសបំពេញបន្ថែម |
| ប្រាក់បំណាច់មាតុភាព | ✓ សេចក្តីចម្លងសំបុត្រកំណើតកូនដាក់ជូនសាមីស្ថាប័នខ្លួន<br>➢ កូនមួយ ( ៨០០,០០០រៀល )<br>➢ កូនភ្លោះពីរ(១,៦០០,០០០រៀល)<br>➢ កូនភ្លោះបី (២,៤០០,០០០រៀល)<br>✓ ទទួលពីស្ថាប័នសាមី | ១.មានគភ៌ចាប់ពី២៦សប្តាហ៍ឡើង<br>២.បង់ភាគទានបាន៩ខែក្នុងកំឡុង រយ:ពេល១២ខែចុងក្រោយគិតរហូតមកទល់ខែបានសម្រាលកូន។ |
| វិភាជន៍បូជាសព | ២លានពីស្ថាប័នសាមី | រង់ចាំប្រកាស |

# ៧.សេវាបន្ទារ

| មន្ត្រីសាធារណៈ | ប្តី ឬប្រពន្ធនិងកូនក្នុងបន្ទុក |
|---|---|
| ប.ស.ស.ផ្តល់ជូនដូចគ្នា | |

# សេវាបង្ការសុខភាពរួមមាន

១-សេវាចាក់វ៉ាក់សាំងការពារជំងឺឆ្កែឆ្កួត (Rabies Vaccination)
២-សេវាចាក់សេរ៉ូមប្រឆាំងជំងឺឆ្កែឆ្កួត (Antirabic Serum)
៣-សេវាចាក់សេរ៉ូមប្រឆាំងជំងឺតេតាណូស (Anti-Tetanus Serum)
៤-សេវាចាក់សេរ៉ូមប្រឆាំងពិសពស់ (Antivenom Immunoglubulin)
៥-សេវាពិនិត្យឈាមរកជំងឺពក ក មាន៖ TSH (Thyroid-Stimulating Hormone), Free T3 (Free Triiodothyronine), Free T4( Free Thyroxine)
៦-សេវាពិនិត្យឈាម កំណត់អបោធាតុមហារីក (Canncer Humeraux Marqueurs) ក្រោយការព្យាបាលជំងឺមហារីកដោយវះកាត់ និង/ឬ ក្រោយការព្យាបាលជំងឺមហារីកដោយចាក់ថ្នាំគីមី និង/ឬក្រោយការព្យាបាលជំងឺមហារីកដោយបាញ់កាំរស្មីអ៊ិច មាន៖ CA15-3 (Canncer Antigen 15-3), CA19-9 (Cancer Antigen19-9), CA125 (Cancer Antigen125), PSA (Prostate-Specific-Antigen), HCG (Beta-Human Chorionic Gonadotropin)

**ចំណាំ៖ សេវាបង្ការដែលបានកំណត់ខាងលើនេះត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាលសាធារណៈ ឬវិទ្យាស្ថានសាធារណៈ។**

# ៨. សេវា ឬការព្យាបាលដែលមិនរាប់បញ្ចូល

មាត្រា១៧នៃអនុក្រឹត្យលេខ១៣៨អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ សេវាខាងក្រោមនេះមិនផ្តល់ជូនសមាជិកប.ស.ស. មានដូចជា៖

- ការព្យាបាលដោយឥតគិតថ្លៃក្នុងគោលនយោបាយសុខាភិបាលជាតិ
- ការថែទាំធ្មេញ (ការសម្អាត ការប៉ះ និងការដាក់ធ្មេញ)
- ការព្យាបាល និងការវះកាត់ប្តូរភេទ
- ការផ្សាំឬប្តូរសរីរាង្គផ្សេងៗ
- សេវាបង្កកំណើតដោយសិប្បនិម្មិត
- ការព្យាបាលដោយខ្លួនឯង
- ការព្យាបាល ឬវះកាត់ដើម្បីកែសម្ផស្សឬកែលម្អផ្នែកណាមួយនៃរាងកាយ
- ការព្យាបាលញៀនសុរាឬការព្យាបាលផ្តាច់គ្រឿងញៀន
- ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត
- ការព្យាបាលការអសមត្ថភាពផ្តល់កំណើត
- ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត
- ការវះកាត់បេះដូង ឬសរសៃឈាមបេះដូង
- ការលាងឈាម
- ការពិនិត្យសុខភាពទូទៅ

ចំណាំ៖ សម្រាប់មុខសេវាខាងលើផ្តល់ជូនតែករណីសង្គ្រោះបន្ទាន់ប៉ុណ្ណោះ។

## ៩. ប្រភេទជំងឺរ៉ាំរ៉ៃ

មាត្រា១៨នៃអនុក្រឹត្យលេខ១៣៨អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧

១-ជំងឺខ្សោយបេះដូង (Cardiac Failure)
២-ជំងឺសាច់ដុំបេះដូង (Cardiomyopathy)
៣-ជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ (Chronic Hepatitis B)
៤-ជំងឺរលាកថ្លើមប្រភេទសេរ៉ាំរ៉ៃ (Chronic Hepatitis C)
៥-ជំងឺតំរងនោមរ៉ាំរ៉ៃ (Chronic renal disease)
៦-ជំងឺក្រិនថ្លើម (Cirrhosis of the liver)
៧-ជំងឺសរសៃឈាមក្រហមបេះដូង (Coronary Artery Disease)
៨-ជំងឺវិបត្តិចង្វាក់បេះដូង (Dysrhythmias)
៩-ជំងឺក្រិនសរីរាង្គ(Multiple Sclerosis)
១០-ជំងឺវិកលចរិត( Schizophrenia)
១១-ជំងឺលុយពុស (Systemic Lupus Erythematosus)
១២-ជំងឺតាឡាសសីមី(Thalassemia)



# ១០.ការទាមទារអត្ថប្រយោជន៍ជាសាច់ប្រាក់

**សមាជិក ប.ស.ស.**

- ដាក់នៅប.ស.ស.ដែលជិតជាងគេ

**ទាមទារជាសាច់ប្រាក់**

- សង្គ្រោះបន្ទាន់
- ប្រាក់បំណាច់មាតុភាព
- ប្រាក់បំណាច់ឈប់សម្រាកពេលមានជំងឺឬគ្រោះថ្នាក់(សហព័ទ្ធនិងកូនក្នុងបន្ទុក មិនទាន់អនុវត្ត)

**ប.ស.ស.**

- មានរយៈពេល១ឆ្នាំគិតចាប់ពីថ្ងៃមានបញ្ហាសុខភាពឬសម្រាលកូន

# II.របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

១.វិសាលភាព
២.និយមន័យហានិភ័យការងារ
៣.លក្ខខណ្ឌចុះបញ្ជីផ្នែកហានិភ័យការងារ
៤.បង់ភាគទាន
៥.អត្ថប្រយោជន៍(តាវកាលិកហានិភ័យការងារ)
៦.ការគណនាប្រាក់បំណាច់ប្រចាំថ្ងៃ វិភាជន៍ និងធនលាភបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍
៧.ការផ្តល់វិភាជន៍បូជាសព ការផ្តល់និងការគណនាធនលាភឧត្តរជីវី

# ១.វិសាលភាព

## បុគ្គលសាធារណៈកំពុងបម្រើការងារនៅតាមស្ថាប័ន អង្គភាព

- ✓ មន្ត្រីរាជការក្នុងក្របខណ្ឌមុខងារសាធារណៈដែលបម្រើការងារនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- ✓ មន្ត្រីរាជការដែលបម្រើការងារក្នុងស្ថាប័ននីតិប្បញ្ញត្តិ
- ✓ មន្ត្រីរាជការដែលបម្រើការងារក្នុងស្ថាប័នតុលាការ
- ✓ មន្ត្រីជាប់កិច្ចសន្យាដែលទទួលស្គាល់ដោយក្រសួងមុខងារសាធារណៈ
- ✓ មន្ត្រីបម្រើការងារនៅ គ.ជ.ប
- ✓ អាជ្ញាធរសវនកម្មជាតិ

# ២.និយមន័យហានិភ័យការងារ

| គ្រោះថ្នាក់ការងារ | | ជម្ងឺវិជ្ជាជីវៈ |
|---|---|---|
| ក្នុងកន្លែងការងារ | កំឡុងពេលធ្វើដំណើរ | ជាជម្ងឺដែលបណ្តាលមកពីវិជ្ជាជីវៈ ក៏ត្រូវចាត់ទុកជាហានិភ័យការងារដែរ។ ធាតុផ្សំដែលអាចកើតមានឡើងមានដូចជា:<br>• ចេញពីកន្លែងការងារ(មុខរបរទាក់ទងជាតិពុលឬតំបន់មិនប្រក្រតីដែលអាចនាំឲ្យកើត ជម្ងឺផ្សេងៗ)<br>• នៅធ្វើការឬឈប់ធ្វើការ |
| គ្រោះថ្នាក់ធ្លាក់លើរូបកាយកម្មករនិយោជិតទោះដោយហេតុណាក៏ដោយពេលបំពេញការងារឲ្យនិយោជក | គ្រោះថ្នាក់ពេលធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ឬ វាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារ ដែលគេតម្រូវឲ្យទៅ ។ | |

# ៣.លក្ខខណ្ឌចុះបញ្ជីផ្នែកហានិភ័យការងារ

| មន្ត្រីសាធារណៈ |
| --- |
| ការចុះបញ្ជីមន្ត្រីសាធារណៈក្នុងប្រព័ន្ធបេឡាជាតិសន្តិសុខសង្គម អនុវត្តដូចគ្នាក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព |
| សហាព័ទ្ធនិងកូនក្នុងបន្ទុក (មិនមានរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ) |

# ៤.បង់ភាគទាន

| មន្ត្រីសាធារណៈ |
| --- |
| រាជរដ្ឋាភិបាលជាអ្នកទទួលបន្ទុកបង់ទាំងស្រុង |
| អត្រាភាគទាន០,២%នៃបៀវត្សមូលដ្ឋានឬប្រាក់កម្រៃ |

# ៥.អត្ថប្រយោជន៍( តាមកាលិកបានិភ័យការងារ )

| មន្ត្រីសាធារណៈ |
| --- |
| ក.សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ |
| ខ.ប្រាក់បំណាច់ប្រចាំថ្ងៃបាត់បង់សមត្ថភាពការងារបណ្ដោះអាសន្ន(រក្សាប្រាក់បៀវត្សនៅដដែល)។ **ករណីធ្ងន់ធ្ងរតម្រូវឲ្យមានអ្នកថែទាំ** ប.ស.ស. ឧបត្ថម្ភដល់អ្នកថែទាំ ៥០% នៃ ៧០%នៃប្រាក់បៀវត្សមូលដ្ឋានឬប្រាក់កម្រៃប្រចាំថ្ងៃរបស់ជនរងគ្រោះនៅក្នុងមន្ទីរពេទ្យ |
| គ.វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ ឬធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ |
| ឃ.សេវាស្ដារនីតិសម្បទា(ផ្នែកវេជ្ជសាស្ត្រ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងសង្គម) |
| ង.វិភាជន៍ជាសោហ៊ុយបូជាសព (១០លានរៀល) |
| ច.ធនលាភឧត្តរជីវីនៃជនរងគ្រោះ |

# ដើម្បីទទួលបានប្រាក់ឧបត្ថម្ភប្រចាំថ្ងៃរបស់អ្នកថែទាំលុះត្រាតែ៖

## ករណីធ្ងន់ធ្ងរតម្រូវឲ្យមានអ្នកថែទាំ

ប.ស.ស. ឧបត្ថម្ភដល់អ្នកថែទាំ ៥០% នៃ ៧០%នៃប្រាក់បៀវត្សមូលដ្ឋានឬប្រាក់កម្រៃប្រចាំថ្ងៃរបស់ជនរងគ្រោះនៅក្នុងមន្ទីរពេទ្យ។

**ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ=ប្រាក់បៀវត្សមូលដ្ឋានឬប្រាក់កម្រៃចែកនឹង២២ថ្ងៃ**

# វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ(ពិការក្រោម២០%)

| |
|---|
| **វិភាជន៍ផ្តល់ជូនតែម្តងគត់** |
| វ.ប.ក=ប.ថ xក.ប.ក x ២០%ម.ត.ប |
| វ.ប.ក គឺជាវិភាជន៍បាត់បង់សមត្ថភាពការងារ |
| ប.ថ គឺជាប្រៀវត្សប្រចាំថ្ងៃរបស់ជនរងគ្រោះ<br>យកប្រាក់បៀវត្សមូលដ្ឋានចែកនឹង២២ថ្ងៃ |
| ក.ប.ក គឺជាកម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ |
| ម.ត.ប មេគុណតម្លៃបច្ចុប្បន្ន |

# ការគណនា

| មន្ត្រីរាជការមានឋានន្តរស័ក្តិវរៈមន្ត្រីថ្នាក់លេខ២(ក.២.៣) | | | |
|---|---|---|---|
| វ.ប.ក=ប.ថxក.ប.ក x ២០%ម.ត.ប | | | |
| ក.២.៣ | ២៦៣០រៀល x ៤១០= | ១,០៧៨,៣០០រៀល | បៀវត្សមូលដ្ឋាន |
| ប.ថ | ១,០៧៨,៣០០រៀល/២២ថ្ងៃ | ៤៩,០១៣រៀល | |
| ក.ប.ក= | ១៨% | | |
| ម.ត.ប= | ៩៨៥៧(អាយុ៣៥ឆ្នាំ) | | |
| វ.ប.ក= | ៤៩,០១៣រៀលx១៨%២០%៩៨៥៧ | ១៧,៣៩២,៣៦១រៀល | |

# ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពី២០%ឡើង

| ធ.ល=ប.ខx៤/៥ក.ប.ក | | |
|---|---|---|
| ធ.ល | គឺជាធនលាភសម្រាប់បាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ | |
| ប.ខ | គឺជាប្រាក់ខែមូលដ្ឋានប្រចាំខែរបស់ជនរងគ្រោះ | |
| ក.ប.ក | គឺជាកម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍របស់ជនរងគ្រោះ(ឧទា៥០%) | |
| ធ.ល | ១,០៧៨,៣០០រៀលX៤/៥ X ៥០% | ៤៣១,៣២៤រៀល |
| តាវកាលិកត្រូតគ្នារវាងធនលាភ និងប្រាក់សោធន សាមីជនទទួលបានតាវកាលិកតែមួយគត់សម្រាប់ទឹកប្រាក់ណាដែលខ្ពស់ជាងគេ | | |
| ប.ស.សរៀបចំឲ្យមានការពិនិត្យសុខភាព និងសមត្ថភាពការងារឡើងវិញក្នុងរយៈពេល១២ខែយ៉ាងយូរ។ សាមីជនមានកាតព្វកិច្ចមកពិនិត្យសុខភាព និងសមត្ថភាពការងារតាមការកំណត់។ | | |

# ៧.ការផ្ដល់វិភាគទានបូជាសព ការផ្ដល់និងការគណនាធនលាភឧត្តរជីវី

| វិភាជន៍បូជាសព១០លានរៀល | សិទ្ធិទាមទារប្រាក់វិភាជន៍បូជាសពមានរយៈពេល១ឆ្នាំ (អាជ្ញាយុកាល) |
|---|---|

## ធនលាភឧត្តរជីវី(បើក០១ខែម្ដង)

<table>
<tr><td rowspan="2">សិទ្ធិវន្តជនរងគ្រោះមានដូចជា:</td><td>ប្ដីឬប្រពន្ធដែលមានសំបុត្រអាពាហ៍ពិពាហ៍</td><td>កូនមានអាយុត្រឹម២១ឆ្នាំចុះ ដែលមិនទាន់មានគូស្រករមានដូចខាងក្រោម:</td><td>ឪពុកម្ដាយឬជនចាស់ជរា មានអាយុយ៉ាងតិច៦០ឆ្នាំ និងត្រូវនៅក្នុងបន្ទុកផ្ទាល់របស់សាមីជនរងគ្រោះ។</td></tr>
<tr><td colspan="3">-កូននៃសហាព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានត្រឹមត្រូវ។<br>-ករណីលែងលះ ឬករណីមរណៈភាពនៃប្ដីឬប្រពន្ធកូននៃអាពាហ៍ពិពាហ៍ក្រោយក៏មានសិទ្ធិដូចកូនអាពាហ៍ពិពាហ៍ទី១ -កូនចិញ្ចឹមរបស់សាមីជននៃសមាជិកប.ស.ស។<br>-ស្ថានភាពកូនចិញ្ចឹមត្រូវកំណត់ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។<br>-កូនក្នុងបន្ទុកដល់២១ឆ្នាំ ស្ថិតក្នុងការបណ្ដុះបណ្ដាលវិជ្ជាជីវៈឬកូនកំពុងរៀននៅគ្រឹះស្ថានសិក្សាសាធារណៈឬឯកជនទទួលស្គាល់ពីរដ្ឋ ដោយមានលិខិតបញ្ជាក់ការសិក្សាត្រឹមត្រូវ<br>-កូនពិការឬ មានជម្ងឺរ៉ាំរ៉ៃ(ផ្ដល់ជូនអស់មួយជីវិត)។</td></tr>
<tr><td>ផុតរលត់នៃសិទ្ធិការទទួលបានធនលាភឧត្តរជីវី</td><td colspan="3">ទី១. នៅពេលដែលសាមីជនទទួលមរណៈភាព<br>ទី២.ប្ដីឬប្រពន្ធដែលសាមីជនរៀបអាពាហ៍ពិពាហ៍ជាថ្មី។ករណីនេះសាមីជនត្រូវជូនដំណឹងមកប.ស.សយ៉ាងយូរ ៣០ថ្ងៃបន្ទាប់ពីថ្ងៃចុះលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ថ្មី។</td></tr>
</table>

# ការគណនាធនលាភឧត្តរជីវី

## កាផ្តល់ធនលាភនេះត្រូវធ្វើឡើងក្នុងមួយខែម្តង

| ប្តីឬប្រពន្ធ កូន និង ឪពុកម្តាយឬមនុស្សចាស់ជរា | ប្តីឬប្រពន្ធនិងកូន | ប្តីឬប្រពន្ធនិង ឪពុក ម្តាយ ឬមនុស្សចាស់ជរា | ប្តីឬ ប្រពន្ធ ឬកូន | ឪពុកម្តាយឬ មនុស្សចាស់ជរា | កូន និងឪពុកម្តាយ ឬមនុស្សចាស់ជរា |
|---|---|---|---|---|---|
| -ប្តី=៣/៥x៦៣%ប.ខ<br>-កូន=២/៥X៦៣%ប.ខ<br>-ឪពុកម្តាយ=៧%ប.ខ | -ប្តី=៣/៥X៧០%ប.ខ<br>-កូន=២/៥X៧០%ប.ខ | -ប្តី=២៨%ប.ខ<br>-ឪពុកម្តាយ=២៨%ប.ខ | -៥៦%ប.ខ | -៣៥%ប.ខ | -កូន=២៨%ប.ខ<br>-ឪពុកម្តាយ=២៨%ប.ខ |

ប.ខជាបៀរវត្សមូលដ្ឋានប្រចាំខែរបស់សាមីជន។ឧទា.ក.២.៣=១,០៧៨,៣០០រៀល

# III.កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២(ពីរ)ឆ្នាំ

| ១.ស្ថាប័នប្រតិបត្តិករ |
| --- |
| ២.វិសាលភាព |
| ៣.លក្ខខណ្ឌទទួលបានប្រាក់ឧបត្ថម្ភ |
| ៤.ការផ្តល់ប្រាក់ឧបត្ថម្ភ |
| ៥.បែបបទ និងនីតិវិធីទទួលបានប្រាក់ឧបត្ថម្ភ |
| ៦.កាលបរិច្ឆេទអនុវត្ត |

# ១.ស្ថាប័នប្រតិបត្តិករ

| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
|---|
| បេឡាជាតិសន្តិសុខសង្គម |
| ១.នាយកដ្ឋានគាំពារការលិកសន្តិសុខសង្គម<br>២.នាយកដ្ឋានសេវាមូលដ្ឋានសុខាភិបាល<br>៣.សាខា ប.ស.ស. ខេត្ត ក្រុង ស្រុក ខណ្ឌ |

# ២.វិសាលភាព

| វិសាលភាពអនុវត្តមកលើបុគ្គល ដូចខាងក្រោម៖ |
|---|
| ➢ កម្មករនិយោជិតជាស្ត្រីដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងមានសញ្ជាតិខ្មែរ |
| ➢ មន្ត្រីរាជការក្នុងក្របខណ្ឌមុខងារសាធារណៈបម្រើការងារនៅតាមក្រសួងស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា<br>➢ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាបម្រើការងារនៅតាមក្រសួងស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលទទួលស្គាល់ដោយក្រសួងមុខងារសាធារណៈ |

# ៣.លក្ខខណ្ឌដើម្បីទទួលបានប្រាក់ឧបត្ថម្ភ

| ស្ត្រីជាសមាជិកប.ស.ស. | កូនរបស់សមាជិក |
|---|---|
| ➢ ត្រូវមានបណ្ណសមាជិក **ប.ស.ស.** និងមានសុពលភាពប្រើប្រាស់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ<br>➢ ត្រូវពិនិត្យផ្ទៃពោះនៅមូលដ្ឋានសុខាភិបាលសាធារណៈ ដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.** ដោយមានភ្ជាប់មកជាមួយនូវសៀវភៅសុខភាពមាតាដែលចេញដោយមូលដ្ឋានសុខាភិបាលសាធារណៈ | កូនដែលម្តាយបានចុះឈ្មោះក្នុងកម្មវិធីរួច កូននោះត្រូវបានចុះឈ្មោះជាស្វ័យប្រវត្តិ ដោយភ្ជាប់មកជាមួយនូវបណ្ណសុខភាពកុមារ។ |

# ៤.ការផ្តល់ប្រាក់ឧបត្ថម្ភ

## មុនសម្រាល

- គភ៌តិចជាង១២សប្តាហ៍
- គភ៌អាយុ២០ទៅ២៤សប្តាហ៍
- គភ៌អាយុ៣០ទៅ៣២សប្តាហ៍
- គភ៌អាយុ៣៦ទៅ៣៨សប្តាហ៍
- **ផ្តល់ជូន៤ដងសរុបទឹកប្រាក់៣២០,០០០រៀល**

## ពេលសម្រាល

- តាមភាពជាក់ស្តែង
- ពេលសម្រាលកូន ទទួលបានប្រាក់ឧបត្ថម្ភ កូនចំនួន ១នាក់ ទទួលបានថវិកា ៨០ម៉ឺនរៀល
- កូនភ្លោះ ២នាក់ ទទួលបានថវិកា ១,៦ លានរៀល
- កូនភ្លោះ ៣នាក់ ទទួលបានថវិកា ២,៤ លានរៀល។
- ទទួលពីស្ថាប័នអង្គភាពសាមី

## ក្រោយសម្រាល

- ថ្ងៃទី៧ក្រោយសម្រាល
- ថ្ងៃទី១៤ក្រោយសម្រាល
- កូនមានអាយុ១ខែកន្លះ
- កូនមានអាយុ២ខែកន្លះ
- កូនមានអាយុ៣ខែកន្លះ
- កូនមានអាយុ៦ខែ
- កូនមានអាយុ៩ខែ
- កូនមានអាយុ១២ខែ
- កូនមានអាយុ១៨ខែ
- កូនមានអាយុ២៤ខែ
- **ផ្តល់ជូន១០ដងសរុបទឹកប្រាក់៨០០,០០០រៀល**

# ការផ្តល់ប្រាក់ឧបត្ថម្ភករណីរលូតកូន

| តិចជាង១២សប្តាហ៍ | ចន្លោះ១២សប្តាហ៍ដល់២៨សប្តាហ៍ |
|---|---|
| ត្រូវផ្តល់ជូន៨០ ០០០ (ប្រាំបីម៉ឺន)រៀល ចំនួន១ (មួយ)លើកគត់។ | គតិអាយុពី១២(ដប់ពីរ)សប្តាហ៍ដល់២៨(ម្ភៃប្រាំបី)សប្តាហ៍ ផ្តល់ជូន<br>➢ ៨០ ០០០(ប្រាំបីម៉ឺន)រៀលពេលរលូត<br>➢ លើកទី២ ជូន៨០ ០០០(ប្រាំបីម៉ឺន)រៀល នៅពេលពិនិត្យសុខភាពក្រោយរលូត។ |

# កូនស្លាប់ពេលសម្រាលឬក្រោយសម្រាល និងម្ដាយស្លាប់ពេលសម្រាល

| កូនស្លាប់ពេលសម្រាលនិងក្រោយសម្រាល | ម្ដាយស្លាប់ពេលសម្រាល |
|---|---|
| ប្រាក់ឧបត្ថម្ភត្រូវបន្តផ្ដល់ជូនដូចខាងក្រោម៖<br>✓ សម្រាលកូនទោល (មួយ) ទទួលបាន ៨០០ ០០០ (ប្រាំបីសែន)រៀល<br>✓ សម្រាលកូនភ្លោះ (ពីរ) ទទួលបាន ១ ២០០ ០០០ (មួយលានពីរសែន)រៀល<br>✓ សម្រាលកូនភ្លោះ (បី) ទទួលបាន ១ ៦០០ ០០០ (មួយលានប្រាំមួយសែន)រៀល<br>ផ្ដល់ប្រាក់ប្រាក់ឧបត្ថម្ភចំនួន ៨០ ០០០(ប្រាំបីម៉ឺន) រៀល ក្នុង១(មួយ)លើក និងផ្ដល់ជូនជាអតិបរមា ចំនួន៣(បី)លើក នៅពេលម្ដាយមកទទួលសេវាពិនិត្យសុខភាពក្រោយពេលសម្រាល។ | ប្រាក់ឧបត្ថម្ភត្រូវបន្តផ្ដល់ជូនដូចខាងក្រោម៖<br>✓ សម្រាលកូនទោល (មួយ) ទទួលបាន ៨០០ ០០០ (ប្រាំបីសែន)រៀល<br>✓ សម្រាលកូនភ្លោះ (ពីរ) ទទួលបាន ១ ២០០ ០០០ (មួយលានពីរសែន)រៀល<br>✓ សម្រាលកូនភ្លោះ (បី) ទទួលបាន ១ ៦០០ ០០០ (មួយលានប្រាំមួយសែន)រៀល។<br>ផ្ដល់ប្រាក់ប្រាក់ឧបត្ថម្ភចំនួន ៨០ ០០០(ប្រាំបីម៉ឺន)រៀល ក្នុង១(មួយ)លើក និងផ្ដល់ជូនជាអតិបរមាចំនួន ១០ (ដប់)ដង នៅពេលយកកូនមកទទួលថ្នាំបង្ការរហូតដល់អាយុ២(ពីរ)ឆ្នាំ។ |

ឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ ២៥២/២៣ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០២៣
ស្តីពីការអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ
និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ

## តារាងកម្មវិធីដែលសាមីខ្លួនទទួលបានប្រាក់ឧបត្ថម្ភ

| ដំណាក់កាល | ចំនួនលើក | ពេលវេលាទៅពិនិត្យសុខភាព |
|---|---|---|
| **ដំណាក់កាលទី១** | ពិនិត្យផ្ទៃពោះលើកទី១ | មានគភ៌អាយុតិចជាង១២សប្តាហ៍ |
| | ពិនិត្យផ្ទៃពោះលើកទី២ | មានគភ៌អាយុ២០ទៅ២៤សប្តាហ៍ |
| | ពិនិត្យផ្ទៃពោះលើកទី៣ | មានគភ៌អាយុ៣០ទៅ៣២សប្តាហ៍ |
| | ពិនិត្យផ្ទៃពោះលើកទី៤ | មានគភ៌អាយុ៣៦ទៅ៣៨សប្តាហ៍ |
| **ដំណាក់កាលទី២** | ពេលសម្រាលកូន | តាមភាពជាក់ស្តែង |
| **ដំណាក់កាលទី៣** | ពិនិត្យសុខភាពក្រោយសម្រាលលើកទី១ (ពិនិត្យទាំងម្តាយ និងកូន) | ថ្ងៃទី៧ក្រោយសម្រាល |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី២ (ពិនិត្យទាំងម្តាយ និងកូន) | ថ្ងៃទី១៤ក្រោយសម្រាល |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៣ (ពិនិត្យទាំងម្តាយ និងកូន) | កូនមានអាយុ១ខែកន្លះ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៤ (ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន) | កូនមានអាយុ២ខែកន្លះ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៥ (ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន) | កូនមានអាយុ៣ខែកន្លះ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៦ (ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន) | កូនមានអាយុ៦ខែ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៧ (ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន) | កូនមានអាយុ៩ខែ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៨ (ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន) | កូនមានអាយុ១២ខែ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៩ (ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន) | កូនមានអាយុ១៨ខែ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី១០ (ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន) | កូនមានអាយុ២៤ខែ |

ឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ ២៥២/២៣ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០២៣
ស្តីពីការអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ
និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ

## តារាងកម្មវិធីទទួលបានប្រាក់ឧបត្ថម្ភករណីកូនរលូត កូនស្លាប់ពេលសម្រាល និងម្តាយស្លាប់ក្នុងពេលសម្រាល

| ដំណាក់កាល | ចំនួនលើក | ពេលវេលាទៅពិនិត្យសុខភាព |
|---|---|---|
| **ពិនិត្យផ្ទៃពោះ** | ពិនិត្យផ្ទៃពោះលើកទី១គភ៌រលូត | មានគភ៌អាយុតិចជាង១២សប្តាហ៍ |
| | ពិនិត្យផ្ទៃពោះរួចគភ៌រលូត | គភ៌អាយុ១២សប្តាហ៍ក្រោម២៤សប្តាហ៍ |
| | ក្រោយរលូតពិនិត្យសុខភាពលើកទី២ | តាមការកំណត់របស់ពេទ្យជាលើកទី២ (ចុងក្រោយ) |
| **កូនស្លាប់ពេលសម្រាល** | កូនស្លាប់ពេលសម្រាល | តាមភាពជាក់ស្តែង |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី១ | តាមការកំណត់របស់ពេទ្យ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី២ | តាមការកំណត់របស់ពេទ្យ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៣ | តាមការកំណត់របស់ពេទ្យ(ផ្តល់ជូនជាលើកចុងក្រោយ) |
| **ម្តាយស្លាប់ពេលសម្រាល** | ពិនិត្យសុខភាពកូនលើកទី១ | ថ្ងៃទី៧ក្រោយសម្រាល |
| | ពិនិត្យសុខភាពកូនលើកទី២ | ថ្ងៃទី១៤ក្រោយសម្រាល |
| | ពិនិត្យសុខភាពកូនលើកទី៣ | កូនមានអាយុ១ខែកន្លះ |
| | ពិនិត្យសុខភាពកូនលើកទី៤ | កូនមានអាយុ២ខែកន្លះ |
| | ពិនិត្យសុខភាពកូនលើកទី៥ | កូនមានអាយុ៣ខែកន្លះ |
| | ពិនិត្យសុខភាពកូនលើកទី៦ | កូនមានអាយុ៦ខែ |
| | ពិនិត្យសុខភាពកូនលើកទី៧ | កូនមានអាយុ៩ខែ |
| | ពិនិត្យសុខភាពកូនលើកទី៨ | កូនមានអាយុ១២ខែ |
| | ពិនិត្យសុខភាពកូនលើកទី៩ | កូនមានអាយុ១៨ខែ |
| | ពិនិត្យសុខភាពកូនលើកទី១០(ចុងក្រោយ) | កូនមានអាយុ២៤ខែ |

# ៥.បែបបទនិងនីតិវិធីទទួលបានប្រាក់ឧបត្ថម្ភ

| ដំណាក់កាលមុនសម្រាល | ដំណាក់កាលពេលសម្រាល | ដំណាក់កាលក្រោយសម្រាល |
| --- | --- | --- |
| ផ្តល់ជូនអតិបរមាចំនួន៤លើក<br>• បែបបទទាមទារពិនិត្យលើកទី១<br>• បែបបទទាមទារលើកទី២ និងទី៣<br>• បែបបទទាមទារលើកទី៤ | តាមពេលវេលាជាក់ស្តែង | ផ្តល់ជូនអតិបរមា ១០ដង |

# ដំណាក់កាលមុនសម្រាល

| លើកទី១ | លើកទី២ និងទី៣ | លើកទី៤ |
|---|---|---|
| សមាជិកត្រូវបំពេញទម្រង់ចំណុចដូចខាងក្រោម:<br>➢ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ<br>➢ បណ្ណសមាជិក **ប.ស.ស.**<br>➢ លេខទូរសព្ទ និងលេខគណនីធនាគារកំណត់ដោយ **ប.ស.ស.**<br>➢ សៀវភៅសុខភាពមាតាបញ្ជាក់ពីអាយុគភ៌ដំបូង ចេញដោយមូលដ្ឋានសុខាភិបាលសាធារណៈ។ | សមាជិក **ប.ស.ស.** ជាស្ត្រីត្រូវទទួលបានប្រាក់ឧបត្ថម្ភលើកទី២ លើកទី៣ តាមរយៈកម្មវិធីភ្នាក់ងារ **ប.ស.ស.** លើទូរសព្ទដៃ (NSSF Agent App)។<br>សមាជិក **ប.ស.ស.** ជាស្ត្រី មិនចាំបាច់មក**ប.ស.ស.**ទៀតទេ។ | សមាជិក ត្រូវបំពេញទម្រង់ស្នើសុំប្រាក់ឧបត្ថម្ភ បន្ទាប់ពីបានពិនិត្យផ្ទៃពោះរួចដោយភ្ជាប់មកជាមួយនូវៈ<br>➢ បណ្ណ**សមាជិក ប.ស.ស.**<br>➢ សៀវភៅសុខភាពមាតាបញ្ជាក់ពីអាយុ៣៦(សាមសិបប្រាំមួយ) ទៅ៣៨(សាមសិបប្រាំបី)សប្តាហ៍របស់គភ៌ដែលចេញដោយមូលដ្ឋានសុខាភិបាលសាធារណៈ។ |

# ដំណាក់កាលសម្រាលកូន

| សមាជិក ប.ស.ស. ត្រូវស្នើសុំប្រាក់ឧបត្ថម្ភសម្រាប់ពេលសម្រាលកូន នូវចំណុចដូចខាងក្រោម៖ |
|---|
| ➢ទម្រង់ "**ស្នើសុំប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីពេលសម្រាលកូន**" |
| ➢ភ្ជាប់សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតឬសេចក្តីចម្លងសំបុត្រកំណើត។ |

# ដំណាក់កាលក្រោយសម្រាល

- សមាជិក **ប.ស.ស**. ជាស្រ្តីត្រូវទទួលបានប្រាក់ឧបត្ថម្ភក្រោយពេលសម្រាល តាមរយៈកម្មវិធី "ភ្នាក់ងារ **ប.ស.ស**. លើទូរសព្ទដៃ (NSSF Agent App)" ។

- កូនរបស់សមាជិក **ប.ស.ស**. ត្រូវទទួលបានប្រាក់ឧបត្ថម្ភនៅពេលយកកូនមកទទួលថ្នាំបង្ការសុខភាព នៅមូលដ្ឋានសុខាភិបាលសាធារណៈ តាមរយៈកម្មវិធី "ភ្នាក់ងារ **ប.ស.ស**. លើទូរសព្ទដៃ (NSSF Agent App)"។

# ករណីរលូតកូន

| តិចជាង១២សប្តាហ៍ | ចន្លោះ១២សប្តាហ៍ដល់២៨សប្តាហ៍ |
|---|---|
| បំពេញទម្រង់ស្នើសុំដោយភ្ជាប់មកជាមួយនូវ៖<br>➢ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ<br>➢ បណ្ណសមាជិក **ប.ស.ស.**<br>➢ លេខទូរសព្ទ និងលេខគណនីធនាគារដែលកំណត់ដោយ **ប.ស.ស.**<br>➢ លិខិតបញ្ជាក់រលូតកូនដែលចេញដោយមូលដ្ឋានសុខាភិបាលសាធារណៈ។ | ១.សាមីខ្លួនមិនចាំបាច់មកទីស្នាក់ការ **ប.ស.ស.**<br>២.សាមីខ្លួនត្រូវពិនិត្យសុខភាពម្តងទៀតក្រោយពេលរលូតកូន (តាមការណាត់របស់ពេទ្យ) |

# កូនស្លាប់ពេលសម្រាល និងម្ដាយស្លាប់ក្នុងពេលសម្រាល

| កូនស្លាប់ពេលសម្រាល | ម្ដាយស្លាប់ពេលសម្រាលនិងក្រោយសម្រាល |
|---|---|
| ប្ដីឬប្រពន្ធត្រូវបំពេញចំណុចដូចជា:<br>➢ ទម្រង់ "**ស្នើសុំប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីពេលសម្រាលកូន**"<br>➢ ភ្ជាប់នូវសេចក្ដីចម្លងសំបុត្រមរណភាពឬលិខិតបញ្ជាក់មរណភាពរបស់កូនដែលចេញដោយមូលដ្ឋានសុខាភិបាលសាធារណ:។<br>➢ លេខគណនីធនាគារដែលកំណត់ដោយ ប.ស.ស. របស់ប្ដី ឬប្រពន្ធ។ | ប្ដី ឬអ្នកតំណាងស្របច្បាប់ត្រូវបំពេញចំណុចដូចជា:<br>➢ ទម្រង់ "**ស្នើសុំប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីពេលសម្រាលកូន**"<br>➢ ភ្ជាប់នូវសេចក្ដីចម្លងសំបុត្រមរណភាពរបស់ម្ដាយ<br>➢ លេខគណនីធនាគារដែលកំណត់ដោយ ប.ស.ស. របស់ប្ដីឬអ្នកតំណាងស្របច្បាប់។ |

# ៦.កាលបរិច្ឆេទអនុវត្ត

- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម២ (ពីរ)ឆ្នាំ ត្រូវចាប់ផ្ដើមអនុវត្តពី**ថ្ងៃទី១ ខែសីហា ឆ្នាំ២០២៣ តទៅ**។

# សំណួរ ចម្លើយ
# សូមអរគុណ!

**បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)**

ទីស្នាក់ការកណ្តាលនៅភូមិបន្លាស្អិត  សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

Website: www.nssf.gov.kh/ Facebook Page: facebook.com/nssfpage/ Hotline: 1286